ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.ធ៧១៣-០៧១-៣៩៧.ស.អ.ជា

ថ្ងៃចន្ទ ១៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១

# សេចក្ដីជូនដំណឹង
## សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៨ ឆ្នាំ២០២១
## ស្ដីពី "បញ្ហាប្រឈមនិងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា"

៙៙៙✵៙៙៙

នៅកម្ពុជា សហគ្រាសធុនតូចនិងមធ្យមមានប្រមាណលើសពី ៩០% នៃសហគ្រាសសរុប ដែលបានរួមចំណែកជិត ៦០% នៃផលិតផលក្នុងស្រុកសរុប និងបង្កើតការងារជាង ៧០% នៃការងារសរុប។ កន្លងមក សហគ្រាសធុនតូចនិងមធ្យមបានរួមចំណែកដល់ការលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្រ ជាពិសេសក្នុងចំណោមប្រជាពលរដ្ឋរស់នៅតាមទីជនបទ។ ទោះជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រយ៉ាងណាក្ដី ការសិក្សាពីស្ថានភាពសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជាបានបង្ហាញថា សហគ្រាសធុនតូចនិងមធ្យមមានបញ្ហាប្រឈមច្រើនក្នុងអាជីវកម្ម ហើយមានឧបសគ្គក្នុងការអភិវឌ្ឍខ្លួនប្រកបដោយចីរភាព។

លើសពីនេះ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងខ្លាំងបន្ថែមទៀត ដល់ការធ្វើអាជីវកម្មរបស់សហគ្រាសធុនតូចនិងមធ្យម ដែលមានភាពងាយរងគ្រោះទៅនឹងការប៉ះទង្គិចស្រាប់។ ក្នុងបរិការណ៍នេះ ដើម្បីរួមចំណែកក្នុងការបង្កើនការសិក្សាស្រាវជ្រាវដែលនៅមានតិចនៅឡើយអំពីការអភិវឌ្ឍនិងពង្រឹងភាពធន់នៃសហគ្រាសធុនតូចនិងមធ្យម ធនាគារជាតិនៃកម្ពុជាបានជ្រើសរើសយកប្រធានបទស្រាវជ្រាវរបស់សន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៨ នាឆ្នាំ២០២១ ស្ដីពី **"បញ្ហាប្រឈមនិងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា" (Challenges for Cambodian SMEs development and policy options)**។

ដូចរៀងរាល់ឆ្នាំដែរ សន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៨ មានគោលបំណងលើកកម្ពស់ការស្រាវជ្រាវលើប្រធានបទខាងលើ និងផ្ដល់ជាវេទិកាពិភាក្សាជុំវិញបញ្ហាប្រឈមនិងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា ដែលអាចក្លាយជាធាតុចូលក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឱ្យកាន់តែមានភាពធន់និងប្រកបដោយបរិយាបន្នខ្ពស់។ សន្និសីទនេះក៏មានការចូលរួមពីអ្នកជំនាញ អ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិផងដែរ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

បេក្ខជនអាចជ្រើសរើសប្រធានបទដែលមានការពាក់ព័ន្ធនឹងប្រធានបទគោលខាងលើ ឬជ្រើសរើសយកប្រធានបទណាមួយក្នុងចំណោមប្រធានបទខាងក្រោម ៖

- តួនាទីរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានិងបញ្ហាប្រឈម
- ផលិតភាពនិងភាពប្រកួតប្រជែងក្នុងការនាំចេញនៃសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា
- ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ មកលើសហគ្រាសធុនតូចនិងមធ្យមតាមវិស័យនានា
- ការប្រើប្រាស់ប្រព័ន្ធឌីជីថលនិងការធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម និង
- ការលើកកម្ពស់សហគ្រិនស្ត្រីនៅក្នុងសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។

បេក្ខជនដែលមានចំណាប់អារម្មណ៍អាចផ្ញើប្រវត្តិរូបសង្ខេប និងសំណើស្រាវជ្រាវរបស់ខ្លួន ឬអត្ថបទស្រាវជ្រាវពេញលេញមកកាន់អគ្គនាយកដ្ឋានបច្ចេកទេស។ សំណើស្រាវជ្រាវដែលផ្ញើមក គួរមានបរិបទនៃការសិក្សាស្រាវជ្រាវ ដែលរួមមានចំណោទបញ្ហា, គោលបំណងនៃការស្រាវជ្រាវ, សម្មតិកម្ម និងការរួមចំណែកនៃអត្ថបទក្នុងការស្រាវជ្រាវកន្លងមក។

**កាលបរិច្ឆេទសំខាន់ៗ៖**

- ការផុតកំណត់នៃការទទួលសំណើស្រាវជ្រាវ៖ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១
- ការជូនដំណឹងស្ដីពីសំណើស្រាវជ្រាវដែលត្រូវបានជ្រើសរើស៖ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១
- ការផុតកំណត់នៃការទទួលអត្ថបទស្រាវជ្រាវពេញលេញ៖ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១
- ការរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៨៖ ខែធ្នូ ឆ្នាំ២០២១។

ធនាគារជាតិនៃកម្ពុជានឹងជ្រើសរើសយកអត្ថបទស្រាវជ្រាវដែលមានគុណវុឌ្ឍិដើម្បីចូលរួមធ្វើបទបង្ហាញនៅក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៨នេះ។ ម្ចាស់អត្ថបទស្រាវជ្រាវដែលបានធ្វើបទបង្ហាញនៅក្នុងសន្និសីទនឹងទទួលបាននូវរង្វាន់លើកទឹកចិត្ត ហើយអត្ថបទស្រាវជ្រាវនឹងត្រូវបានបោះផ្សាយជាអត្ថបទស្រាវជ្រាវរបស់ធនាគារជាតិនៃកម្ពុជា។

**អគ្គនាយកដ្ឋានបច្ចេកទេស**

សូមទំនាក់ទំនងមក៖
ធនាគារជាតិនៃកម្ពុជា
អគ្គនាយកដ្ឋានបច្ចេកទេស
លេខទូរស័ព្ទ៖ ០៩២ ៧៧៩ ៨៧៨/ ០១០ ៨៥៨ ៨៨៦
អ៊ីម៉ែល៖ macroconfer@nbc.org.kh